# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ទូរគមនាគមន៍កម្ពុជា**

លេខ : ៦២.៤៧.ទ.ក.........

## សូមគោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**កម្មវត្ថុ**: ស្តីពីការពន្យល់បំភ្លឺរបស់ទូរគមនាគមន៍កម្ពុជាទៅកាន់អ្នកសារព័ត៌មាន ដែលសរសេរខុសពីការពិត អំពីទីតាំងសាងសង់អគារថ្មី នៅឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

**យោង** : ចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៤។

**ភ្ជាប់ជូន**: អត្ថបទសារព័ត៌មានដើមអំពិល ចំនួន ០១ ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជំរាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា: នៅមុនពេលប្រារព្ធពិធីបញ្ចុះបឋមសិលាសាងសង់អគារថ្មី សំរាប់បំរើសេវាទូរគមនាគមន៍ក្នុងគម្រោង CP-P5 ចំនួន ០៣ ថ្ងៃ មានគេហទំព័រមួយបានចុះផ្សាយព័ត៌មានមិនពិត សំដៅលើលោកប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ ថាទីតាំងសាងសង់អគារថ្មី នៅឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ទំនងជាបានលក់ទៅឲ្យឈ្មួញឯកជនធ្វើស្ថានីយ៍លក់ប្រេងឥន្ទនៈបាត់ទៅហើយ ព្រោះគេបានឃើញអតីតសំណង់ការិយាល័យ ប.ទ ស្រុកព្រៃនប់ត្រូវបានវាយកំទេចរួចជាស្ថាពរ ម្លោះហើយការសង្ស័យរឿងមិនល្អធ្វើឲ្យមហាជនទូទៅមានការភ័ន្តច្រលំលោក យស់ សុជា ប្រធាមន្ទីរ ប.ទ ខេត្តព្រះសីហនុបានចូលរាយការណ៍ និងសុំអនុសាសន៍បំភ្លឺពី ឯកឧត្តមអភិបាលខេត្តព្រះសីហនុ។

ហើយនៅថ្ងៃប្រារព្ធពិធីបញ្ចុះបឋមសីលាសាងសង់អគារថ្មីទាំងនៅព្រៃនប់ និងទីរួមខេត្តព្រះសីហនុ លោកប្រធានមន្ទីរ ប.ទ ខេត្តបានសុំការអនុញ្ញាតឲ្យរូបខ្ញុំបាទបាននិយាយពន្យល់ និងបញ្ជាក់ប្រាប់ក្រុមអ្នកសារព័ត៌មាន និង អ្នកថតទូរទស្សន៍ CTN និង CNC រួចអស់ហើយអំពីដីនោះ គឺត្រូវការសាងសង់ជាអគាររដ្ឋបាល អាជីវកម្ម និងបច្ចេកទេស សំរាប់ទូរគមនាគមន៍កម្ពុជា ដោយគម្រោងកម្ចីពីរដ្ឋាភិបាលជប៉ុន (CP-P5) សំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នងពីទីរួមខេត្តកំពង់ចាមរហូតដល់ខេត្តព្រះសីហនុ មានអគារដែលត្រូវសាងសង់ថ្មីចំនួន ១០ ទីតាំង ដោយបានបង្ហាញប្លង់អគារសាងសង់ជូនអ្នកសារព័ត៌មានទាំងអស់ មានក្រុមហ៊ុនម៉ៅការសាងសង់ និងទីប្រឹក្សាជប៉ុនចូលរួមជាសាក្សីផងដែរ។ ក្រោយពីការស្រាយបំភ្លឺនេះពួកគាត់ក៏បានយល់ច្បាស់ និងបានចុះផ្សាយកែតម្រូវក្នុងគេហទំព័រដើមអំពិល នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១៤ ដូចមានអត្ថបទព័ត៌មានភ្ជាប់ជូនមកជាមួយ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដោយអនុគ្រោះ។

សូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក ទ.ក.**

ទ.ក.

T.C.

Telecom Cambodia

**ឡាយ ហ៊ារីទ្ធី**

<u>ចម្លងជូន:</u>

-ឯកឧត្តមប្រធានក្រុមប្រឹក្សាភិបាលទ.ក.

-ក្រុមអ្នកនាំពាក្យក្រសួង ប.ទ

"ដើម្បីគោរពជូនជ្រាប"

-ឯកសារ-កាលប្បវត្តិ


អាស័យដ្ឋានលេខ ៩៥-៩៧ វិថីព្រះសីហនុ កែងផ្លូវលេខ ១០៥ សង្កាត់ បឹងព្រលឹត ខណ្ឌ ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: (៨៥៥) ២៣ ៧២០១២០

ទូរសារ: (៨៥៥) ២៣ ៧២៧១៦៨